


# ចាញ់ឈ្នះ-ឈ្នះចាញ់

ប្រជាពលរដ្ឋខ្មែរ បានចូលរួមបោះឆ្នោតជ្រើសរើស ទីព្រឹក្សា ឃុំ-សង្កាត់ សំរាប់ អណត្តិទី៤ កាលពីថ្ងៃ ទី៤ មិថុនា ឆ្នាំ ២០១៧។ តាម ទិដ្ឋភាពក្រៅ នៃ ការបោះឆ្នោត វាឃើញមាន ដំណើរ រលូន តែ ទិដ្ឋភាពក្នុង វា គ្មានអ្នកណា អាចដឹងជម្រៅវាបាននោះឡើយ ព្រោះនៅស្រុកខ្មែរ ជាស្រុកដឹកនាំដោយ របបចោរម៉័ទ (kleptocratie) គឺថា អ្វីក៏អាច ទិញដូរ ឬ លួច តាមសេរី គ្មានទោសភ័យ នៅចំពោះមុខច្បាប់ ដែល ពួកអ្នកកាន់អំណាចផ្តាច់ការ គេបកស្រាយវាតាមចិត្តដែលគេចង់បាន និង តុលាការពុករលួយ ហើយ រណបអំណាច និង នៅក្រោម ឥទ្ធិពលសំណូក។ ដូច្នេះមិនត្រូវទុកលទ្ធផល នៃ ការបោះឆ្នោតជាការពិត ១០០% នោះឡើយ ព្រោះ វាជា ការបោះឆ្នោត នៅក្នុង អភិក្រម សម្រួលដោយ អំណាចផ្តាច់ការ និង បរិបទ សម្លុតបំភ័យ ក្នុងរយៈពេលដ៏យូរមួយ តាមគ្រប់មធ្យោបាយ នៅមុនពេលបោះឆ្នោត ដើម្បី ទាញយក អត្ថប្រយោជន៍ដល់ខ្លួន។

ទោះយ៉ាងនេះក្តី លទ្ធផល បង្ហាញថា គណបក្សសង្គ្រោះជាតិ មានកើនចំនួន ឃុំ-សង្កាត់ ជាក់ស្តែង រីឯ គណបក្សប្រជាជនកម្ពុជា វិញ បាត់ ឃុំ-សង្កាត់ មួយចំនួនធំ ជា ពិសេស នៅ ទីក្រុង ភ្នំពេញ និង បណ្តាខេត្ត មួយចំនួន ដែល មាន ប្រជា

## ចាញ់ឈ្នះ-ឈ្នះចាញ់

ពលរដ្ឋ រស់នៅច្រើន តែនៅអាចថែរក្សា ចំនួន លើសដាច់ ពី គណបក្សសង្គ្រោះជាតិ[1]។ ចំពោះ លោក យឹម សុវណ្ណ អ្នកដឹកនាំម្នាក់ នៃ គណបក្សសង្គ្រោះជាតិ យល់ឃើញថា លទ្ធផលនេះ វាអាចទុក ជា ជ័យជំនះ ជាការលើកទឹកចិត្ត រហូត ហ៊ានព្រាងទុក ថា គណបក្សគាត់ នឹងឈ្នះឆ្នោត នៅពេលបោះឆ្នោតជាតិនៅឆ្នាំ ២០១៨។ ដូច្នេះ លទ្ធផល នៃ ការបោះឆ្នោត ត្រូវ គ.ស.ជ. អាចទទួលយកបាន។ រីឯ គ.ប.ជ.ក. វិញ ក៏ទុកលទ្ធផលនេះ ជាជ័យជំនះ របស់ខ្លួននោះដែរ ព្រោះខ្លួន ឈ្នះចំនួន ឃុំ-សង្កាត់ទោះបី ចំនួននោះ ចុះថយក៏ដោយ។ តែ ចំណុចរួម របស់ គណបក្សទាំងពីរ គឺ ការទទួលស្គាល់លទ្ធផល នៃ ការបោះឆ្នោត។ ដូច្នេះ គោលដៅចម ដែល លោក ហ៊ុន សែន ចង់បាន វា បានសម្រេចមែន គឺ ដំណើរ វិជ្ជមាន នៃ ការបោះឆ្នោត ដែល សហគមអន្តរជាតិ អាចនឹង ទទួលស្គាល់បាន។ ជ័យជំនះនេះ វាជាឈានឫទ្ធិ របស់ យួន អាចបន្ត គ្មានឧបសគ្គ នូវ នយោបាយបញ្ចូល ស្រុកខ្មែរ ទៅក្នុង មហាវៀកណាម តាមមធ្យោបាយបញ្ចូល ប្រជាជនយួន មានចំនួន ក្រៃមុះហិម្មា មកក្នុងស្រុកខ្មែរ ដើម្បី រស់នៅ ជា ប្រជាជនកម្ពុជា ដែលជា ប្រជាជន សំរាប់បោះឆ្នោត ឲ គ.ប.ជ.ក. និយមយួន និង ជា អ្នកត្រួសត្រាយវាតទឹកដីខ្មែរ។ ដូច្នេះ ការបោះឆ្នោត នៅឆ្នាំ ២០១៧-២០១៨ ដែល គ.ស.ជ.ខ. ចុះចូល ហ៊ុនសែន ទុកជា ជ័យជំនះ និង បន្ត

---

[1] គណបក្សប្រជាជនកម្ពុជា: ១.១៥៨ ឃុំ-សង្កាត់; គណបក្សសង្គ្រោះជាតិ: ៤៨៧ ឃុំ-សង្កាត់។

## ចាញ់ឈ្នះ-ឈ្នះចាញ់

មាន ជ័យជំនះម្តងទៀត ជា រូបបំភាន់ភ្នែក សំរាប់ ប្រជាជាតិខ្មែរ ព្រោះ មោទនា នោះ វាជា អាភៀន សំរាប់ ធ្វើអោយអន់ឈឺចាប់ ជម្ងឺ យួនលួចស្រុក រហូតសណ្តំសតិ ឲលែងទុកវាជា បញ្ហានៃ អាយុជីវិតជាតិ ព្រោះ គ្រឿងញៀននេះ វាបង្កើតឲមាន មរិចិកា (mirage) ឃើញ ស្រុក មាន សន្តិភាព មាន យួនកុះករ អាចបោះឆ្នោតបាន។ ទោះបីយ៉ាងណាក៏ដោយ ក៏ខ្មែរយើង នាំគ្នាទុក ការបោះឆ្នោតបែបនេះ ជា មហោសថ សំរាប់ ព្យាបាលជម្ងឺខ្មែរ។

ដូច្នេះ ឈ្នះចាញ់-ចាញ់ឈ្នះ របស់ លោក ហ៊ុន សែន និង លោក កឹម សុខា វាជា ដំណើរ ពុំអាចថយក្រោយបាន នៃ អវសាន នៃ ប្រជាជាតិខ្មែរ។ ត្រូវដឹងថា ខ្មែរយើង ទាំងអស់គ្នា ជា អ្នកទទួលខុសត្រូវ នៅចំពោះមុខ បាតុភូត នេះ ដែលយើងពុំអាចជឿបានថាវា ជា សច្ចះភាព សំរាប់ ប្រជាជាតិខ្លួន។ នៅពេលដែលប្រព័ន្ធ នៃ ជាតិសាសន៏មួយ វា គ្មាន សមត្ថភាព ដោះស្រាយ ជីវបញ្ហា (problèmes vitaux) របស់ខ្លួន, ប្រព័ន្ធនោះ វា ធ្វើឲអន់ថយដោយខ្លួនឯង, បែកខ្ញែក, ឬ ផ្តុយទៅវិញ វាសំដែងឲឃើញសម្ថភាព អាចបំផុះ ឧត្តម-ប្រព័ន្ធ (méta-système) មួយថ្មី សំរាប់ ដោះស្រាយ បញ្ហា។ តែ នៅក្នុង ករណីមួយណាក៏ដោយ វា ធ្វើឲផ្លាស់ប្តូរដោយខ្លួនឯង នូវ អត្តវត្តុ នៃ ប្រព័ន្ធ ជាចាំបាច់។ ដូរពី ល្អ ទៅជា មិនល្អ ឬ មិនល្អ ទៅជា ល្អ វា អាស្រ័យ ទៅលើកម្លាំង នៃ បដិសរីរៈ របស់ ប្រព័ន្ធ នៃ ជាតិសាសន៏ នោះឯង។ អ្វី ដែល បវរ វាតែងតែ មាន ជ័យជំនះ ជានិច្ច៕ ឲ